ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 02 / 2015
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ចន្ទ ទី ២៦ ខែ មករា ឆ្នាំ ២០១៥

## សវនាការលើភស្តុតាង - ថ្ងៃ ២៣៣

រៀបចំដោយ៖ សែ កុលវុឌ្ឍី និង **Matthew McCARTHY**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម ធូ មណី (ជំនួសចៅក្រម យូរ ឧត្តរា) |
| ចៅក្រមបម្រុង៖ ចៅក្រម Martin Karopkin |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា ជា ស៊ីវហ៉ង, លោក Matthew McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicolas KOUMJIAN, លោក សេង ប៊ុនឃាង, កញ្ញា សុង ឆវ័ន្ត, លោក Dale LYSAK, លោក Joseph Andrew Boyle, លោក Vincent de Wilde d'Estmael, លោក ស្រ៊ា រតនៈ |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួន), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក |

| |
|---|
| ហុង គឹមសួន, លោកស្រី ស៊ីន សុវ៉ន, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោកស្រី ជេត វណ្ណលី, លោក Yiqiang LIU, លោកស្រី ទី ស្រីនណា |
| សាក្សី/ដើមបណ្តឹង៖ អ៊ុំ សុផានី (2-TCCP-296) និង ជូ គឹមឡន (2-TCCP-238) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី ស្វ សុទ្ធារី |
| ផ្សេងៗ៖ កញ្ញា តូច តន់នារី, លោកស្រី ពេជ ចរិយា, កញ្ញា ស្រី ណាក់, លោក មៀច សុវណ្ណា, កញ្ញា សុក សុភ័គមណីកា, កញ្ញា Sara ERJAVEC, |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០៦ | បញ្ចប់ម៉ោង៖ ១៥.១៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៤៤ | បញ្ចប់ម៉ោង៖ ១១.០២ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០១ | បញ្ចប់ម៉ោង៖ ១៣.៣៤ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៨ | បញ្ចប់ម៉ោង៖ ១៥.១១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៣ ម៉ោង និង ៥៥ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៧ | ០៩.០៩ |
| សំណើសុំតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៩ | ០៩.១១ |
| ការប្រើប្រាស់ឯកសារដែលមិនមាននៅក្នុងសំណុំរឿង | អង្គជំនុំជម្រះ<br><br>សហព្រះរាជអជ្ញា<br>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ០៩.១១<br>០៩.៣៥<br>០៩.១៩<br>០៩.២៩ | ០៩.១៤<br>០៩.៣៧<br>០៩.២១<br>០៩.៣១ |
| ការបន្តតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី (2-TCCP-296) | មេធាវីការពារក្តី នួន ជា<br><br>មេធាវីការពារក្តី ខៀវ សំផន | ០៩.១៦<br>១០.១៧<br>១០.០១ | ១០.០១<br>១០.២៥<br>១០.១៦ |

| | | | |
|---|---|---|---|
| | 2-TCCP-296 | ១០.២៦ | ១០.៤២ |
| ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡុន (2-TCCP-238) | អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញា | ១១.០៦<br>១១.១៣<br>១៤.០៣ | ១១.១៣<br>១៤.០៣<br>១៤.៤៧ |
| ការបង្ហាញកំណត់ហេតុស្តាប់ចម្លើយពីសំណុំរឿងលេខ ០០៤ | មេធាវីការពារក្តី នួន ជា<br>សហព្រះរាជអាជ្ញា | ១៣.៣៤<br>១៣.៣៥ | ១៣.៣៥<br>១៣.៤៧ |
| ការផ្អាកសវនាការ និងការផ្លាស់ប្តូរកាលវិភាគសវនាការ | អង្គជំនុំជម្រះ | ១៥.១១ | ១៥.១៣ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធី ដោយជូនដំណឹងពីអវត្តមានរបស់លោកចៅក្រម យូរ ឧត្តរា ហើយជំនួសដោយលោកចៅក្រម ធូ មណី។ បន្ទាប់មកក្រឡាបញ្ជីបានរាយការណ៍ពីស្ថានភាពវត្តមាន និងអវត្តមានរបស់ភាគី ហើយ ជនជាប់ចោទ នួន ជា មានវត្តមានពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>ការលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការរបស់ជនជាប់ចោទ នួន ជា</u>**

ប្រធានអង្គជំនុំជម្រះបានជូនដំណឹងទៅភាគីពីសំណើសុំរបស់ ជនជាប់ចោទ នួន ជា តាមរយៈមេធាវីការពារក្តីរបស់ខ្លួន ក្នុងការលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ មកតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ អង្គជំនុំជម្រះសម្រេចតាមសំណើសុំរបស់ ជនជាប់ចោទ។

**<u>ការប្រើប្រាស់ឯកសារដែលមិនមាននៅក្នុងសំណុំរឿង</u>**

សហព្រះរាជអាជ្ញាបានជំទាស់ចំពោះការតាំងសំណួររបស់មេធាវីការពារក្តី នួន ជា ដោយផ្អែកទៅលើឯកសារដែលមិនមាននៅក្នុងសំណុំរឿង។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជំទាស់ចំពោះការប្រើប្រាស់ឯកសារនេះផងដែរ។ អង្គជំនុំជម្រះ បានរំលឹកទៅភាគីទាំងអស់ថា មានតែឯកសារដែលមាននៅក្នុងសំណុំរឿងប៉ុណ្ណោះ ដែលភាគីអាចប្រើប្រាស់នៅក្នុងសវនាការបាន ហើយភាគីដែលមានបំណងប្រើប្រាស់ឯកសារនេះ ត្រូវដាក់សំណើសុំតាមវិធាន ៨៧.៤ ក្នុងករណីដែលឯកសារនោះមិនមាននៅក្នុងសំណុំរឿង។ ទោះបីជាយ៉ាងណាក៏ដោយ ជាករណីលើកលែង អង្គជំនុំជម្រះអនុញ្ញាតិឲ្យមេធាវី

ការពារក្ដី នួន ជា ដាក់ឯកសារទាំងនោះទៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងរយៈពេល ៤៨ ម៉ោង ព្រមទាំងដាក់សំណើសុំតាមវិធាន៨៧.៤។ អង្គជំនុំជម្រះ បានសម្រេចថា ដើមបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវកោះហៅមកផ្ដល់សក្ខីកម្មឡើងវិញទាក់ទងនឹងសំណួរដែលផ្អែកទៅលើឯកសារទាំងនេះ ប្រសិនបើចាំបាច់។

**ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ សុផានី** (2-TCCP-296)

មេធាវីការពារក្ដី នួន ជា បានបន្តតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ សុផានី បន្ទាប់មកមេធាវីការពារក្ដី ខៀវ សំផន សួរសំណួរបន្ត។ ចុងក្រោយ ដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើការថ្លែងរៀបរាប់អំពីការឈឺចាប់ដែលប៉ះពាល់ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានតាំងសំណួរទៅកាន់ជនជាប់ចោទតាមរយៈប្រធានសវនាការ។ ជនជាប់ចោទ បានរក្សាសិទ្ធិនៅស្ងៀម មិនឆ្លើយតបទៅនឹងសំណួរដែលសួរដោយដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។ ការផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ សុផានី (2-TCCP-296) ត្រូវបានបញ្ចប់។

**ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គីមឡុន** (2-TCCP-238)

អង្គជំនុំជម្រះ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា បានតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី។

**កំណត់ហេតុស្ដាប់ចម្លើយថ្មី ដែលបានស្នើដោយសហព្រះរាជអាជ្ញា**

មេធាវីការពារក្ដី នួន ជា បានស្នើសុំឱ្យការិយាល័យសហព្រះរាជអាជ្ញាធ្វើការបញ្ជាក់ទាក់ទងនឹងការដាក់បង្ហាញឯកសារកំណត់ហេតុស្ដាប់ចម្លើយពីក្នុងសំណុំរឿងលេខ០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ (E319/8)។

**ការប្រកាសផ្អាកសវនាការ និងការផ្លាស់ប្ដូរកាលវិភាគនៃការធ្វើសវនាការ**

អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះនឹងផ្អាកសវនាការនៅពេលនេះដោយសារតែជនជាប់ចោទ ខៀវ សំផន មានបញ្ហាសុខភាព។ អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីថា ចាប់ពីថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ នេះតទៅ សវនាការនៅពេលព្រឹកនឹងចាប់ផ្ដើមពីម៉ោង ០៩.០០ ព្រឹក រហូតដល់ម៉ោង ១១.៣០ នាទី ដើម្បីអនុញ្ញាតិឱ្យជនជាប់ចោទ ខៀវ សំផន ទទួលបានពេលសម្រាកច្រើនជាងមុន ហើយពេលវេលាធ្វើសវនាការនៅពេលរសៀល មិនមានការផ្លាស់ប្ដូរនោះទេ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| លេខ E3 | លេខកសចស | ចំណងជើង | ចំណាត់ថ្នាក់ | ERN ខ្មែរ | ERN អង់គ្លេស | ERN បារាំង |
|---|---|---|---|---|---|---|

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E323.1.1 | | 01032943-01032959<br>01036454-01036469<br>01036470-01036489 | Contemporaneous Diary of 2-TCCP-296 | P | 01032950<br>01032951<br>01032952 | 01036460<br>01036461<br>01036462 | 01036477<br>01036478<br>01036479<br>01036480 |
| E3/5839 | | 00562744-00562947<br>01037335-01037343<br>01037344-01037351 | Civil Party Application of OUM Suphany 09-VU-03554 | P | 00562857 | 01037338 | 01037346 |
| E3/5469 | | 00506456-00506478<br>00746213-00746228<br>00822236-00822256 | Complaint of CHOU Kim Lan 08-VU-01708 | P | 00506465 | 00746219 | 00822246 |
| E3/135 | | 00062789-00062835<br>00446846-00446883<br>00487707-00487747 | Revolutionary Flag, The Internal Party Magazine published monthly, Issue 6 June 1977 | P | | | |
| E3/289 | | /<br>00168479-00168513<br>/ | Foreign Broadcast Information Service collection of reports for July 1977 | P | N/A | 00168509<br>00168510<br>00168511 | N/A |
| E3/4083 | | 00068024-00068037<br>00323943-00323978<br>00778851-00778879 | Prisoner List | P | 00068026<br>00068030 | 00323948<br>00323961<br>00323962 | 00778854<br>00778865<br>00778866 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- សេចក្តីសម្រេចលើការតែងតាំងចៅក្រម ធូ មណី ជំនួសលោកចៅក្រម យូរ ឧត្តារា នៅក្នុងអំឡុងពេលដែលលោកចៅក្រមអវត្តមាន។
- បង្គាប់ឱ្យអង្គភាពសោតទស្សន៍ភ្ជាប់ឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ។

- ណែនាំឱ្យមេធាវីការពារក្តី នួនជា ដាក់ភស្តុតាងថ្មីផ្អែកតាមវិធាន ៨៧.៤ (០៩.៣៦)។
- សម្រេចផ្អាកសវនាការនៅពេលនេះ ដោយសារតែអវត្តមានជនជាប់ចោទ ខៀវ សំផន (១៥.១៣)។
- សម្រេចកាត់បន្ថយពេលវេលាធ្វើសវនាការនៅពេលព្រឹកចាប់ពីថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ នេះតទៅ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ និងបង្គាប់ឱ្យនាំខ្លួនគាត់ មកសាលសវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ (១៥.១៤)។

| **<u>កាលវេលាសវនាការបន្ត</u>** |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥

| | |
| --- | --- |
| ក្រឡាបញ្ជី | ក្រឡាបញ្ជី |
| សែ កុលទុត្ថា | Matthew McCARTHY |